

# កម្ពុជា និង អ៊ីរី (IRRI)

# ជំរុញផលិតភាពស្រូវ និង សន្តិសុខស្បៀង

## ដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា

- ប្រព័ន្ធកសិកម្មដោយផ្អែកលើស្រូវជាមូលដ្ឋាន បានបង្កើតជាឆ្អឹងខ្នង នៃវិស័យកសិកម្មរបស់ប្រទេសកម្ពុជា។
- វប្បកម្មដំណាំស្រូវនៅប្រទេសកម្ពុជា បែងចែកជាប្រព័ន្ធក្សេត្របរិស្ថានបួនខុសគ្នា៖ ក្សេត្របរិស្ថានស្រែទំនាបទីពឹងរបបទឹកភ្លៀង ក្សេត្របរិស្ថានចម្ការ ក្សេត្របរិស្ថានស្រែជម្រៅ ឬស្រូវឡើងទឹក និង ក្សេត្របរិស្ថានរដូវប្រាំង ។
- ស្រូវត្រូវបានដាំដុះភាគច្រើនក្នុងរដូវវស្សា ហើយគ្របដណ្តប់ ជាង៧៥%នៃបរិមាណផលស្រូវសរុបក្នុងឆ្នាំ។
- ការដាំដុះស្រូវរដូវប្រាំង ក៏នៅតែជាផ្នែកមួយ ដ៏មានសក្តានុពល នៃផលិតកម្មស្រូវ ជាពិសេសគឺសម្រាប់អតិថិជន ដែលមានចំណង់ចំណូលចិត្តប្រភេទពូជស្រូវប្រាំង។
- បច្ចុប្បន្ននេះ កសិករកម្ពុជាបានប្រែក្លាយទៅជាការដាំដុះស្រូវដោយពង្រោះគ្រាប់។
- ទិន្នផលស្រូវនៅក្នុងរដូវប្រាំងទទួលបានខ្ពស់ជាងស្រូវវស្សា ដោយសារតែកសិករប្រើប្រាស់គ្រាប់ពូជទិន្នផលខ្ពស់ និងមានការគ្រប់គ្រងទឹកក្នុងស្រែបានល្អប្រសើរ។
- គិតត្រឹមឆ្នាំ២០១៦ ស្រឡាយបង្កាត់ របស់វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (IRRI) ចំនួន១៧ បានបញ្ចេញឱ្យប្រើប្រាស់ជាពូជស្រូវ នៅក្នុងប្រទេសកម្ពុជា។ ពូជស្រូវទាំងនោះមានដូចជា៖ ពូជសែនពិដោរ អ៊ីរ៉ែ ៦៦ ជលសា ខា១៤ ខា១៥ និងខា១៦ ហើយពូជស្រូវទាំងនោះកំពុងត្រូវបានដាំដុះយ៉ាងទូលំទូលាយដោយកសិករផងដែរ។

វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (IRRI) និង រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការក្នុងភាពជាដៃគូបង្កើតឡើងនូវ ប្រព័ន្ធកសិកម្មដ៏រឹងមាំមួយនៅក្នុងប្រទេសកម្ពុជា អស់រយៈពេលជាង ៣០ឆ្នាំមកហើយ។ ភាពជាដៃគូបានបង្កើតឡើងជាផ្លូវការ តាមរយៈការចុះអនុស្សរណៈនៃការយោគយល់គ្នា នៅក្នុងឆ្នាំ ១៩៨៦ កំប៉ុន្តែការគាំទ្ររបស់អ៊ីរី (IRRI) ចំពោះប្រទេសកម្ពុជា គឺមានតាំងតែពីមុនពេលនោះមកម្លេះ។

អ្នកវិទ្យាសាស្ត្រកម្ពុជាចំនួនប្រាំមួយនាក់ បានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានអ៊ីរី នៅចន្លោះឆ្នាំ១៩៦០ និង១៩៧៣។ វិទ្យាស្ថានអ៊ីរី បានប្រមូលប្រភេទពូជស្រូវខុសៗគ្នានៅក្នុងប្រទេសកម្ពុជា ចាប់ពីខែធ្នូ ឆ្នាំ១៩៧២ ដល់ខែមករា ឆ្នាំ ១៩៧៣ និងបានអភិរក្សពូជស្រូវរបស់ប្រទេសកម្ពុជានៅក្នុងធនាគារពិន្ទុស្រូវអន្តរជាតិ។ ដោយសារតែការ កង្វះស្បៀងអាហារនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ កសិករកម្ពុជាភាគច្រើនបានបង្ខំចិត្តបរិភោគស្រូវពូជរបស់ពួកគេ ដែលធ្វើឲ្យពូជស្រូវប្រពៃណីភាគច្រើនត្រូវបានបាត់បង់។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ វិទ្យាស្ថានអ៊ីរី បាននាំយកពូជស្រូវប្រពៃណីរបស់កម្ពុជាជាង ៧៥០ប្រភេទ ត្រឡប់មកកាន់ប្រទេសកម្ពុជា និងបានធ្វើការដាំដុះឡើងវិញ។

គម្រោង កម្ពុជា-អ៊ីរី-អូស្ត្រាលី (CIAP) បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៨៧ ដោយមានគោលបំណងបង្កើនផលិតកម្មស្រូវ និងផលិតភាពនៃប្រព័ន្ធផលិតកម្មដោយផ្តោតលើស្រូវជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ គម្រោង CIAP បានចាប់ផ្តើមកម្មវិធីបង្កាត់ពូជ ដើម្បីអភិវឌ្ឍពូជស្រូវបសិដ្ឋកម្មសម្រាប់ប្រព័ន្ធក្សេត្របរិស្ថានផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា។ អាស្រ័យដោយការផ្សព្វផ្សាយពូជស្រូវទិន្នផលខ្ពស់ និងការទទួលយកបច្ចេកវិទ្យារបស់ CIAP បានធ្វើឲ្យប្រទេសកម្ពុជាចាប់ផ្តើមនាំចេញអង្ករជាលើកដំបូងទៅកាន់ទីផ្សារអន្តរជាតិនៅក្នុងឆ្នាំ១៩៩៥។

អង្ករដ៏ល្បីល្បាញរបស់កម្ពុជា គឺអង្ករផ្ការំដួល ត្រូវបានជ្រើសរើសជា "អង្ករល្អបំផុតក្នុងពិភពលោក" ចំនួនបីឆ្នាំជាប់ៗគ្នា នៅក្នុងសន្និសីទពាណិជ្ជកម្មស្រូវអង្ករពិភពលោក – នៅបាលី នៅក្នុងឆ្នាំ២០១២ ហុងកុង នៅក្នុងឆ្នាំ២០១៣ នៅភ្នំពេញ នៅក្នុងឆ្នាំ២០១៤ និងថ្មីៗនេះក្នុងឆ្នាំ២០១៨នៅវៀតណាម។ ពូជស្រូវផ្ការំដួលជាប្រភេទពូជក្រអូបប្រណិត ហើយបានបង្កើតឡើងដោយមានការគាំទ្រពីគម្រោងកម្ពុជា-អ៊ីរី-អូស្ត្រាលី និងបានបញ្ចេញជាពូជស្រូវដោយនាយកដ្ឋានក្សេត្រសាស្ត្រនៅក្នុងឆ្នាំ១៩៩៩។

ខែឧសភា ឆ្នាំ២០២០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះហត្ថលេខាជាមួយវិទ្យាស្ថានអ៊ីរីលើផែនការកិច្ចសហប្រតិបត្តិការឆ្នាំ២០២០ - ២០២៣។ ឯកសារនេះបានក្លាយជាផែនទីតម្រង់ផ្លូវសម្រាប់ជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការកម្ពុជា អ៊ីរី ក្នុងប្រព័ន្ធស្បៀងកសិកម្មនៅក្នុងប្រទេសកម្ពុជា។

## សមិទ្ធិផលសំខាន់ៗដែលសម្រេចបាន

**ការអភិរក្សពូជស្រូវប្រពៃណី** ផ្នែកមួយនៃដំណើរការមាតុភូមិនិវត្តន៍ក្រោយសង្គ្រាមស៊ីវិល វិទ្យាស្ថានអ៊ីរី បាននាំយកពូជស្រូវប្រពៃណីរបស់កម្ពុជាចំនួន ៧៦៦ពូជ ដែលបានរក្សាទុកនៅក្នុងធនាគារពិន្ទុស្រូវអន្តរជាតិ យកមកដាំដុះឡើងវិញនៅក្នុងប្រទេសកម្ពុជា។ គិតត្រឹមខែកក្កដា ឆ្នាំ២០១៦ មានគ្រាប់ពូជស្រូវរបស់កម្ពុជាចំនួន៤.៨៩៥ ប្រភេទ រក្សាទុកដោយសុវត្ថិភាពនៅក្នុងធនាគារពិន្ទុនេះ។

**ការកែលម្អគ្រឿងយន្តកសិកម្ម** អ៊ីរី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើតេស្តសាកល្បងបច្ចេកវិទ្យានានាក្រោយពេលប្រមូលផល និងវិធីសាស្ត្រធ្វើឱ្យប្រសើរឡើងម៉ាស៊ីនកិនស្រូវ។ អ៊ីរី ក៏បានធ្វើការបង្ហាញ ផ្សព្វផ្សាយ ការប្រើប្រាស់ម៉ាស៊ីនច្រូតស្រូវស្វ័យប្រវត្តិ និងឧបករណ៍សម្ងួតស្រូវ នៅក្នុងប្រទេសកម្ពុជាផងដែរ។ នៅក្នុងឆ្នាំ២០០៩-២០១៣ ធនាគារអភិវឌ្ឍអាស៊ីបានគាំទ្រដល់ការធ្វើតេស្តសាកល្បង និងពង្រីកការផ្សព្វផ្សាយនូវបច្ចេកវិទ្យាទាំងនេះ នៅក្នុងខេត្តគោលដៅចំនួនប្រាំមួយបន្ថែមទៀត។ គិតត្រឹមចុងឆ្នាំ២០១៣ ឧបករណ៍សម្ងួតស្រូវ (flatbed dryers) ប្រមាណ ២០០គ្រឿង បានដំឡើងដោយវិស័យឯកជន និងម៉ាស៊ីនច្រូតស្រូវស្វ័យប្រវត្តិ ប្រមាណ៥.០០០គ្រឿង បានប្រើប្រាស់។ អ៊ីរីបានដឹកនាំសមាគមម៉ាស៊ីនដាំគ្រាប់ស្រូវ (Direct Seeded Consortium) និងគាំទ្រការធ្វើឱ្យប្រសើរឡើងម៉ាស៊ីនដាំគ្រាប់ស្រូវ។

**ការអភិវឌ្ឍសមត្ថភាព** គិតចាប់ពីឆ្នាំ១៩៦៣ រហូតដល់ឆ្នាំ២០១៩ សិក្ខាកាមប្រមាណជាង ៣៤០ នាក់ ពីប្រទេសកម្ពុជា បានចូលរួមនៅក្នុងវគ្គសិក្សារយៈពេលខ្លី និងកម្មវិធីបណ្តុះបណ្តាលនានារបស់អ៊ីរី។ ក្រោយពេលត្រឡប់មកដល់កម្ពុជាវិញ ពួកគាត់បានបណ្តុះបណ្តាលបន្តដល់កសិករនៅក្នុង ៤៦ភូមិ ដែលមានកសិករចូលរួមប្រហែល ១៣.០០០ គ្រួសារ។ ស្ថិតក្រោមកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយអ៊ីរី និស្សិតអាហារូបករណ៍កម្ពុជា ចំនួនប្រាំបួននាក់ (ក្នុងនោះមានថ្នាក់បណ្ឌិតចំនួនប្រាំមួយនាក់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីរនាក់ និងបរិញ្ញាបត្រមួយនាក់) បានបញ្ចប់ការសិក្សាដោយជោគជ័យ។ ក្រៅពីនោះក៏មានកម្មសិក្សាការី និងអ្នកហាត់ការចំនួន៣៥នាក់ផងដែរ។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ គម្រោងនានារបស់វិទ្យាស្ថានអ៊ីរី នៅប្រទេសកម្ពុជាដោយទទួលបានការគាំទ្រពី ធនាគារអភិវឌ្ឍអាស៊ី និងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការ បានជួយបណ្តុះបណ្តាលអ្នកស្រាវជ្រាវ អន្តរការីកសិករ និងអ្នកផលិតបរិក្ខារកសិកម្មចំនួន២៧៦នាក់។

**ការកៀរពង្រាបដីដោយប្រើឡាស៊ែ** នៅឆ្នាំ១៩៩៨ គម្រោង កម្ពុជា អ៊ីរី អូស្ត្រាលី (CIAP) បានធ្វើការតេស្តសាកល្បងបច្ចេកវិទ្យាការកៀរពង្រាបដី នៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រព័ន្ធឡាស៊ែ ។ គិតត្រឹមឆ្នាំ២០០០ វាលស្រែប្រមាណ ២០០ កន្លែង ត្រូវបានកៀរពង្រាបដីដើម្បីបង្ហាញអំពីបច្ចេកវិទ្យា។ តែទោះជាយ៉ាងណាក៏ដោយ ការទទួលយកបច្ចេកវិទ្យានៅពេលនោះនៅមានកម្រិតទាបនៅឡើយ។ នៅឆ្នាំ២០១២គម្រោងរបស់អ៊ីរីដែលគាំទ្រ ដោយធនាគារអភិវឌ្ឍអាស៊ី បានធ្វើការបង្ហាញបច្ចេកវិទ្យាកៀរពង្រាបដីឡើងវិញ ហើយរហូតមកទល់បច្ចុប្បន្ន មានឧបករណ៍កៀរពង្រាបដីដោយប្រើប្រព័ន្ធឡាស៊ែរចំនួនប្រាំបីគ្រឿងកំពុងដំណើរការនៅទូទាំងប្រទេស។


### ទំនាក់ទំនង

បណ្ឌិត យូឌី យ៉ាសមី (Dr. Yurdi Yasmi)

តំណាង អ៊ីរី ប្រចាំតំបន់អាស៊ីអាគ្នេយ៍

អ៊ីមែល៖ y.yasmi@irri.org

**ការិយាល័យ អ៊ីរី ប្រចាំកម្ពុជា**

អគ្គនាយកដ្ឋានកសិកម្ម (GDA)

លេខ៥៤បេ/៤៩អេហ្វ ផ្លូវលេខ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**ការិយាល័យកណ្តាលអ៊ីរី** (ប្រទេសហ្វីលីពីន)

+៦៣ ២ ៥៨០ ៥៦០០

info@irri.org


## កិច្ចសហប្រតិបត្តិការនាពេលបច្ចុប្បន្ន

**ផែនការកិច្ចសហប្រតិបត្តិការ កម្ពុជា អ៊ីរី ២០២០ - ២០២៣** ផែនការនេះគឺដើម្បីជំរុញផែនការកិច្ចសហប្រតិបត្តិការ៖ ១. ជំរុញពាណិជ្ជកម្មស្រូវអង្ករ តាមរយៈការសិក្សាវាយតម្លៃខ្សែច្រវ៉ាក់តម្លៃ ២. ជំរុញផលិតភាព និងភាពធន់នឹងអាកាសធាតុ តាមរយៈការអភិរក្ស និងប្រើសម្ភារកម្មពូជ ការធ្វើឱ្យប្រសើរឡើងផលិតកម្មដំណាំ និងការអភិវឌ្ឍប្រព័ន្ធពូជដំណាំ ៣. ជំរុញការគ្រប់គ្រងដីកសិកម្មតាមរយៈបច្ចេកទេសកសិកម្មវៃឆ្លាតធន់នឹងអាកាសធាតុ ៤. ពិពិធកម្មការគ្រប់គ្រងដីកសិកម្ម ការគ្រប់គ្រងសណ្ឋានដី ការរៀបចំប្រព័ន្ធគំរូ និងការរៀបចំផែនការ ៤. លើកកម្ពស់ទំនើបកម្មកសិកម្ម តាមរយៈការប្រើប្រាស់គ្រឿងយន្តកសិកម្ម ការគ្រប់គ្រងក្រោយប្រមូលផល និងការគ្រប់គ្រងផលិតផលរង (By-product)។

**យុទ្ធសាស្ត្រពូជដំណាំជាតិ** អ៊ីរី បានគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រពូជដំណាំជាតិជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា។ ផែនការនេះនឹងជួយធ្វើឲ្យមានទំនើបកម្មវិស័យពូជដំណាំ តាមរយៈការបង្កើតនាយកដ្ឋានពូជដំណាំ និងលើកកម្ពស់ឧស្សាហកម្មពូជដំណាំជាលក្ខណៈពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា។

**ការផ្សព្វផ្សាយពូជស្រូវធន់នឹងលក្ខខណ្ឌមិនអំណោយផល និងសត្វល្អិត** ក្រោមកិច្ចសហប្រតិបត្តិការជាមួយដៃគូទាំងវិស័យឯកជន និងសាធារណៈ អ៊ីរីបានជំរុញផ្សព្វផ្សាយពូជស្រូវទិន្នផលខ្ពស់ ធន់នឹងទឹកជំនន់ និងភាពរាំងស្ងួត រួមបញ្ចូលការអនុវត្តបង្កុំបច្ចេកទេសដាំដុះនៅក្នុងផលិតកម្មស្រូវរបស់កសិករ។ អ៊ីរី រួមជាមួយដៃគូនានាថ្នាក់ជាតិ បានអនុវត្តការត្រួតពិនិត្យប្រព័ន្ធជំងឺ (http://webapps.irri.org/pathotracer/) និងចាប់ផ្តើមអភិវឌ្ឍពូជស្រូវធន់ដែលនឹងអាចផ្សព្វផ្សាយសម្រាប់ដាំដុះបានក្នុងលក្ខខណ្ឌជាក់លាក់នៅក្នុងប្រទេសកម្ពុជា។

**វិធានការចម្រុះគ្រប់គ្រងសមាសភាពចង្រៃលើដំណាំស្រូវ** (IPM) តាមរយៈគម្រោងនានា អ៊ីរី និងដៃគូ បានបង្កើតកញ្ចប់បច្ចេកទេសសមស្របគ្រប់គ្រងសមាសភាពចង្រៃ ដើម្បីកាត់បន្ថយការបាត់បង់ទិន្នផលស្រូវនៅក្នុងប្រទេសកម្ពុជា ដែលបង្កឡើងដោយសមាសភាពចង្រៃ ព្រមទាំងកិច្ចការពារសុខុមាលភាពសហគមន៍ជនបទ និងបរិស្ថានរបស់ពួកគេ។ តាមរយៈកិច្ចការទាំងនេះ ប្រព័ន្ធអេកូឡូស្ទ្របរិស្ថានដំណាំស្រូវកាន់តែមានភាពស៊ាំទៅនឹងសមាសភាពចង្រៃ និងថែរក្សាសត្វនៅក្នុងធម្មជាតិ តាមរយៈសពាង្គកាយ(សត្វ)មានប្រយោជន៍។

**ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យពីចម្ងាយ** វិទ្យាស្ថានអ៊ីរី និងដៃគូរបស់ខ្លួនកំពុងធ្វើកិច្ចការកាត់បន្ថយភាពងាយរងគ្រោះរបស់កសិករខ្នាតតូច តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាប្រព័ន្ធគ្រប់គ្រងទិន្នន័យពីចម្ងាយ ដើម្បីរៀបចំផែនទី និងសង្កេតអំពីការដុះលូតលាស់ដំណាំស្រូវនៅក្នុងប្រទេស។ ព័ត៌មានដែលប្រមូលបានតាមរយៈបច្ចេកវិទ្យាទាំងនេះ នឹងជួយដល់រាជរដ្ឋាភិបាលដើម្បីប្រើប្រាស់ជាទិន្នន័យមូលដ្ឋាន ដូចជាការដោះស្រាយបញ្ហាចំបងនៃការកង្វះស្បៀងអាហារ ឬការផ្តួចផ្តើមការធានារ៉ាប់រងដំណាំ (Crop insurance)។

**ការគ្រប់គ្រងចំបើង.** ជម្រើសនានាសម្រាប់បង្កើនការគ្រប់គ្រងចំបើងស្រូវ គឺជាមធ្យោបាយមួយសម្រាប់កសិករក្នុងការបង្កើនប្រាក់ចំណូលបន្ថែម និងការទទួលយកការអនុវត្តសម្រាប់ការបញ្ចេញសារធាតុកាបូនក្នុងកម្រិតទាប និងនិរន្តរភាពនៃប្រព័ន្ធផលិតកម្មដោយផ្អែកលើស្រូវជាមូលដ្ឋាន។ វិទ្យាស្ថានអ៊ីរី កំពុងរៀបចំចងក្រងឯកសារស្រាវជ្រាវ និងធ្វើការសិក្សាបន្ថែម ដែលនឹងធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយនាពេលអនាគត។

**ការកាត់បន្ថយ និងបន្សាំការប្រែប្រួលអាកាសធាតុ** កិច្ចខិតខំប្រឹងប្រែងនានារួមមានការបង្កាត់ពូជ និងការអភិវឌ្ឍពូជស្រូវសម្រាប់បន្សាំ និងមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការស្រាវជ្រាវប្រព័ន្ធពិពិធកម្មនានា និងរៀបចំបង្កើតគោលនយោបាយដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនោះ។

**ការធ្វើឲ្យប្រសើរឡើងកម្រិតជីវភាពរស់នៅរបស់កសិករ** ការរួមបញ្ចូលវិធីសាស្ត្រចម្រុះដើម្បីជួយដល់កសិករផលិតស្រូវ នៅក្នុងលក្ខខណ្ឌស្រោចស្រព និងលក្ខខណ្ឌបរិស្ថានមិនអំណោយផល ដើម្បីកាត់បន្ថយហានិភ័យនានា និងធ្វើឲ្យប្រសើរឡើងផលិតភាពកសិកម្មតាមរយៈការជំរុញ ការធ្វើបច្ចុប្បន្នភាព និងការផ្សព្វផ្សាយបច្ចេកវិទ្យាថ្មីៗ។

IRRI International Rice Research Institute

ខែតុលា ឆ្នាំ២០២០

**វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (អ៊ីរី)**

វិទ្យាស្ថានអ៊ីរី មានគោលបំណងធ្វើឲ្យប្រសើរឡើងជីវភាពរស់នៅ និងអាហារូបត្ថម្ភ ការកាត់បន្ថយភាពក្រីក្រ ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅក្នុងចំណោមប្រជាជន ដែលពឹងផ្អែកលើប្រព័ន្ធកសិចំណីអាហារដោយផ្តោតលើស្រូវជាមូលដ្ឋាន។ អាស្រ័យដោយគោលបំណងនេះ កិច្ចការជាអាទិភាពរបស់អ៊ីរី គឺកិច្ចការពារសុខុមាលភាពដល់កសិករផលិតស្រូវ និងអ្នកបរិភោគ និងនិរន្តរភាពបរិស្ថាននៃផលិតកម្មស្រូវនៅក្នុងពិភពលោក ដែលកំពុងប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ លើសពីនេះការងាររបស់អ៊ីរី គឺលើកកម្ពស់ការផ្តល់អំណាចដល់ស្ត្រី និងគាំទ្រការផ្តល់ឱកាសនានាប្រកបដោយសមធម៌សម្រាប់យុវជនចូលរួមនៅក្នុងប្រព័ន្ធកសិចំណីអាហារ។